**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# គោលនយោបាយ

# ស្តីពី

# ប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ខែតុលា ឆ្នាំ២០១៤**

# អារម្ភកថា

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានតម្រូវឲ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនានា។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា និងតម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងសម្រាប់កំណត់អំពីសក្តានុពលនៃធនធាន និងអន្តរាគមន៍ចាំបាច់នានា ដើម្បីដោះស្រាយនូវបញ្ហានានា សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពទាំងនោះយ៉ាងមានប្រសិទ្ធភាព។

ដើម្បីជួយឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួនប្រកបដោយសនិទានភាព និងភាពស័ក្តិសិទ្ធិ ស្របតាមចរិតលក្ខណៈដោយឡែកៗពីគ្នានៃរដ្ឋបាលនីមួយៗ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវ **ឯកសារគោលនយោបាយស្តីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ដោយបានកំណត់នូវទស្សនវិស័យ គោលបំណង គោលដៅ គោលការណ៍ និងយុទ្ធសាស្ត្រនានាសម្រាប់ផ្តល់ការណែនាំតម្រង់ទិសដល់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីបង្កើនប្រសិទ្ធភាពនៃការធ្វើសេចក្តីសម្រេចចិត្តដោយស្វ័យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងបង្កើនប្រសិទ្ធភាពនៃការសម្របសម្រួល ការកៀរគរការគាំទ្រពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានាក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងការជំរុញកិច្ចអភិវឌ្ឍមូលដ្ឋានប្រកបដោយភាពស័ក្តិសិទ្ធិ តាមរយៈការរៀបចំ និងអនុវត្តនូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងក្រសួងផែនការដែលបានដឹកនាំ សម្របសម្រួលការរៀបចំឯកសារគោលនយោបាយដ៏មានសារសំខាន់នេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាដែលបានចូលរួមចំណែកគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់នឹងបន្តការគាំទ្រ និងចូលរួមចំណែកក្នុងការរៀបចំ និងអនុវត្តនូវប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនេះ ដើម្បីធានាដល់ការចូលរួមសម្រេចបាននូវគោលបំណងនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិយ៉ាងពិតប្រាកដ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី..១៧..ខែ..វិច្ឆិកា...ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា


១. សេចក្តីផ្តើម ...... ១
២. សនិទានភាព ...... ២
៣. ចក្ខុវិស័យ ...... ៣
៤. គោលបំណង និងគោលដៅ ...... ៣
 ៤.១. គោលបំណង ...... ៣
 ៤.២. គោលដៅ ...... ៣
៥. វិសាលភាព ...... ៣
៦. គោលការណ៍នៃប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ...... ៣
 ៦.១. ស្វ័យភាពមូលដ្ឋាន ...... ៣
 ៦.២. អភិបាលកិច្ច ...... ៤
 ៦.៣. ការឆ្លើយតប ...... ៤
 ៦.៤. ប្រភេទផែនការតាមប្រភេទរដ្ឋបាលនីមួយៗ ...... ៤
៧. យុទ្ធសាស្ត្រ ...... ៥
 ៧.១. យុទ្ធសាស្ត្រទី១ ៖ ការរៀបចំផែនការទៅតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ...... ៥
 ៧.២. យុទ្ធសាស្ត្រទី២ ៖ ការរៀបចំ និងកែសម្រួលស្ថាប័នកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ ...... ៦
 ៧.៣. យុទ្ធសាស្ត្រទី៣ ៖ ការរៀបចំ និងកែសម្រួលឧបករណ៍កសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ ...... ៧
 ៧.៤. យុទ្ធសាស្ត្រទី៤ ៖ ការរៀបចំ និងកែសម្រួលក្របខ័ណ្ឌពេលវេលាកសាងផែនការ រដ្ឋបាលថ្នាក់ក្រោមជាតិ ...... ៨
 ៧.៥. យុទ្ធសាស្ត្រទី៥ ៖ ការរៀបចំស្ថាប័នគាំទ្រការកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ ...... ៩
៨. ផែនការសកម្មភាព ...... ៩
៩. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ...... ១០
១០. សេចក្តីសន្និដ្ឋាន ...... ១០

# គោលនយោបាយ
# ស្តីពី
# ប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ១. សេចក្តីផ្តើម

ការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាជំហានមួយក្នុងដំណើរការកំណែទម្រង់អភិបាលកិច្ចថ្នាក់មូលដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅពង្រឹងការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចនៅតាមមូលដ្ឋាន និងដើម្បីកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

ក្នុងការអនុវត្តប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តម្រូវឲ្យមានការពង្រឹងការអនុវត្តខ្សែគណនេយ្យភាព តម្លាភាព ការឆ្លើយតបប្រកបដោយសមធម៌ និងការចូលរួមពីសំណាក់ប្រជាពលរដ្ឋទាំងស្ត្រី និងបុរស។ តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ក្នុងឆ្នាំ២០០២ ប្រព័ន្ធកសាងផែនការថ្នាក់ឃុំ សង្កាត់ត្រូវបានរៀបចំ និងដាក់ឲ្យប្រើប្រាស់ដែលប្រព័ន្ធកសាងផែនការនេះ គឺជាឧបករណ៍ដ៏មានសារៈសំខាន់មួយសម្រាប់កិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន ក៏ដូចជាការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន។

ដោយផ្អែកលើបទពិសោធន៍នៃការអនុវត្តកំណែទម្រង់វិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលកម្ពុជាបានពង្រីកវិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិទាំងមូល តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌលើកដំបូងក្នុងឆ្នាំ២០០៩។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះ គឺជានីតិបុគ្គលនៃនីតិសាធារណៈ ដែលមានសិទ្ធិអំណាច មានធនធាន និងមានស្វ័យភាពក្នុងការសម្រេចចិត្តក្រោមក្របខ័ណ្ឌនៃច្បាប់ជាតិ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការជំរុញកិច្ចអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ ក្នុងបរិការនេះ តម្រូវឲ្យមានការរៀបចំប្រព័ន្ធអភិបាលកិច្ចដែលមានលក្ខណៈសមស្រប និងឆ្លុះបញ្ចាំងពីចរិតលក្ខណៈផ្សេងៗគ្នារបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនោះ។

ប្រព័ន្ធកសាងផែនការ ជាប្រព័ន្ធអភិបាលកិច្ចចាំបាច់ និងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រព័ន្ធនេះពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចចិត្តតាមបែបប្រជាធិបតេយ្យ ការកំណត់ចក្ខុវិស័យ គោលបំណង គោលដៅ និងក្របខ័ណ្ឌអភិវឌ្ឍន៍ ដែលក្រុមប្រឹក្សាពាក់ព័ន្ធចង់សម្រេចបានក្នុងអាណត្តិរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់មូលដ្ឋាន និងប្រទេសជាតិ។

ឯកសារគោលនយោបាយនេះ នឹងផ្តល់គោលការណ៍សម្រាប់ការរៀបចំប្រព័ន្ធកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងដើម្បី

បង្កើនប្រសិទ្ធភាពនៃការធ្វើសេចក្តីសម្រេចចិត្តដោយស្វ័យភាពរបស់ក្រុមប្រឹក្សានីមួយៗ ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ការជំរុញកិច្ចអភិវឌ្ឍមូលដ្ឋានប្រកបដោយភាពស័ក្តិសិទ្ធិ។

## ២. សនិទានភាព

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់ បានតម្រូវឲ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ រៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងក្នុង និងក្រៅដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅមូលដ្ឋាន។

កន្លងមក ដើម្បីជួយឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់) ធ្វើការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានាត្រូវបានរៀបចំ និងដាក់ឲ្យប្រើប្រាស់ជាបន្តបន្ទាប់។ ប៉ុន្តែលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាទាំងនោះពុំទាន់បានកំណត់ឲ្យបានច្បាស់លាស់អំពីបែបបទនីតិវិធីនៃការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគទៅតាមចរិតលក្ខណៈនៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយប្រកបដោយស្វ័យភាព និងដើម្បីសម្របសម្រួលគ្នាទៅវិញទៅមកដោយស្មើភាព រួមទាំងការសម្របសម្រួលផ្នែកថវិកានៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ម្យ៉ាងវិញទៀត ក្នុងដំណើរការកសាងផែនការរបស់ខ្លួន ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗពុំទាន់មានលទ្ធភាពក្នុងការអនុវត្តស្វ័យភាពថវិការបស់ខ្លួន ដោយសារតែក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងធនធានផ្ទាល់របស់មូលដ្ឋាន និងប្រព័ន្ធគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់ត្រូវបានរៀបចំ និងដាក់ឲ្យប្រើប្រាស់។ ការខ្វះខាតទាំងនេះ គឺជាមូលហេតុដែលធ្វើឲ្យវិសាលភាពនៃការអនុវត្តផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសថ្នាក់ក្រុង ស្រុកមានការលំបាក និងបានត្រឹមតែព្យាយាមសុំការវិភាជន៍ធនធានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានដូចជា ក្រសួង ស្ថាប័ននានា អង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានាប៉ុណ្ណោះ។

គោលនយោបាយនេះ នឹងផ្តល់ជាទស្សនទាន និងចង្អុលបង្ហាញដល់ការរៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាឲ្យមានភាពសមស្របទៅនឹងស្មារតីនៃច្បាប់រៀបចំអង្គការ ក៏ដូចជាកំណត់ច្បាស់អំពីប្រភេទផែនការអភិវឌ្ឍន៍មូលដ្ឋាននានា ដែលឆ្លុះបញ្ចាំងតាមចរិតលក្ខណៈផ្សេងៗគ្នារបស់រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិសម្រាប់ការកៀរគរ និងការវិភាជន៍ធនធានពីក្រសួង ស្ថាប័ន ពីអ្នកពាក់ព័ន្ធនានា និងសម្រាប់ការវិភាជន៍ និងការប្រើប្រាស់ធនធានផ្ទាល់ខ្លួនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

## ៣. ចក្ខុវិស័យ

ប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការឯកភាពគ្នា ស៊ីសង្វាក់គ្នា និងស្របតាមចរិតលក្ខណៈដោយឡែកៗនៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ សម្រាប់ជាមូលដ្ឋានក្នុងការប្រើប្រាស់ និងបែងចែកធនធានដែលមាននៅមូលដ្ឋាន និងធនធានដែលទទួលបានពីប្រភពផ្សេងៗទៀត សំដៅឆ្លើយតបតម្រូវការអភិវឌ្ឍន៍នៅមូលដ្ឋានប្រកបដោយសមធម៌ ប្រសិទ្ធភាព ភាពសក្ដិសិទ្ធិ និងដោយមានយកចិត្តទុកដាក់ជាចម្បងទៅលើការរក្សាបាននូវលំនឹងបរិស្ថានធម្មជាតិ។

## ៤. គោលបំណង និងគោលដៅ

### ៤.១. គោលបំណង

គោលនយោបាយនេះមានគោលបំណង ផ្ដល់ការណែនាំជាគោលនយោបាយសម្រាប់ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធ និងកិច្ចដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានស្វ័យភាពក្នុងការរៀបចំផែនការក្នុងអាណត្តិក្រុមប្រឹក្សារបស់ខ្លួន ដោយត្រូវធ្វើការបញ្ចូលនូវគោលនយោបាយ និងផែនការអភិវឌ្ឍន៍របស់វិស័យទាំងឡាយដែលប្រតិបត្តិការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឲ្យមានភាពស៊ីសង្វាក់គ្នាលើការចែករំលែកការទទួលខុសត្រូវ ក្នុងការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍របស់មូលដ្ឋាន និងរួមចំណែកក្នុងការសម្រេចបាននូវគោលដៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិផងដែរ។

### ៤.២. គោលដៅ

ដើម្បីសម្រេចបានគោលបំណងខាងលើ គោលនយោបាយនេះបានកំណត់គោលដៅជាក់លាក់ចំនួនពីរ ៖

- **ទីមួយ ៖** ផ្ដល់ការណែនាំសម្រាប់ការពិនិត្យ និងការកែលម្អប្រព័ន្ធ និងនីតិវិធីនៃការកសាងផែនការតាមចរិតលក្ខណៈផ្សេងៗគ្នានៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- **ទីពីរ ៖** ផ្ដល់ការណែនាំអំពីយន្តការ និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំកសាង និងការអនុវត្តផែនការរបស់ខ្លួន។

## ៥. វិសាលភាព

គោលនយោបាយនេះ មានវិសាលភាពគ្របដណ្ដប់លើប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល ដែលរួមមាន រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់។

## ៦. គោលការណ៍នៃប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៦.១. ស្វ័យភាពមូលដ្ឋាន

រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជានីតិបុគ្គលនៃនីតិសាធារណៈ ដែលត្រូវបំពេញមុខងាររបស់ខ្លួនក្នុងក្របខ័ណ្ឌច្បាប់ជាតិ និងស្ថិតក្រោមការត្រួតពិនិត្យនីត្យានុកូលភាពរបស់រាជរដ្ឋាភិបាល។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានស្វ័យភាពក្នុងការកសាងផែនការ និងចាត់ចែងធនធានផ្ទាល់របស់ខ្លួន(ធនធាន

ដែលទទួលបានពីថ្នាក់ជាតិ ធនធានដែលប្រមូលនិងគៀរគរបានក្នុងមូលដ្ឋាន) ដើម្បីអនុវត្តមុខងារដែលបានប្រគល់ ឬធ្វើប្រតិភូកម្ម និងមុខងារជាជម្រើសរបស់ខ្លួន ក្នុងការឆ្លើយតបនឹងតម្រូវការអាទិភាពរបស់មូលដ្ឋាន។

## ៦.២. អភិបាលកិច្ច

កំណែទម្រង់វិមជ្ឈការនៅព្រះរាជាណាចក្រកម្ពុជា បានបង្កើតឲ្យមានប្រព័ន្ធអភិបាលកិច្ចនៅច្រើនថ្នាក់រដ្ឋបាល ដែលថ្នាក់រដ្ឋបាលនីមួយៗទទួលខុសត្រូវក្នុងការរៀបចំ និងការអនុវត្តគោលនយោបាយនានា ដោយសហការជាមួយរដ្ឋបាលប្រភេទដូចគ្នា និងរដ្ឋបាលប្រភេទផ្សេងគ្នា។ ក្នុងបរិបទនេះ រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័ននានានៅថ្នាក់ក្រោមជាតិ ត្រូវបែងចែកការទទួលខុសត្រូវប្រកបដោយតម្លាភាព ប្រសិទ្ធភាព កិច្ចសហការ ការសម្របសម្រួល និងមានគណនេយ្យភាពក្នុងការកសាងផែនការទៅតាមសមត្ថកិច្ចរបស់ខ្លួន។

## ៦.៣. ការឆ្លើយតប

ផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវឆ្លើយតបនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ជាមួយនឹងការចូលរួមការពារធនធានធម្មជាតិដែលមានសក្តានុពលយូរអង្វែង និងការចូលរួមចំណែកសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ជាឯកសារណែនាំ និងតម្រង់ទិសដល់មន្ទីរ អង្គភាពជំនាញក្នុងការឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដ និងជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានផងដែរ។

## ៦.៤. ប្រភេទផែនការតាមប្រភេទរដ្ឋបាលនីមួយៗ

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវរៀបចំផែនការរបស់ខ្លួនឲ្យស្របតាមចរិតលក្ខណៈនៃប្រភេទរដ្ឋបាលរបស់ខ្លួន។ បណ្តារដ្ឋបាលថ្នាក់ក្រោមជាតិ គឺជានីតិបុគ្គលដែលមានប្រព័ន្ធរដ្ឋបាល និងអភិបាលកិច្ចផ្សេងៗគ្នា ប៉ុន្តែមានទំនាក់ទំនងគ្នាក្នុងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលគ្នាទៅវិញទៅមក។ ប្រព័ន្ធនេះត្រូវបានរៀបចំឡើងស្របតាមចរិតលក្ខណៈខុសៗគ្នារបស់មូលដ្ឋានដូចជា ផែនការសម្រាប់រាជធានី ផែនការសម្រាប់ខេត្ត ផែនការសម្រាប់ក្រុង និងសង្កាត់ និងផែនការស្រុក និងឃុំ ជាដើម។

ប្រភេទផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះរួមមាន ៖

១. ផែនការរាជធានី

២. ផែនការខេត្ត

៣. ផែនការទីប្រជុំជន (ក្រុង និងសង្កាត់)

៤. ផែនការទីជនបទ (ស្រុក និងឃុំ)

## ៧. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង គោលដៅ និងគោលការណ៍ដែលបានកំណត់ខាងលើ គោលនយោបាយនេះកំណត់យកយុទ្ធសាស្ត្រសំខាន់ៗចំនួន០៥ ដូចខាងក្រោម ៖

- រៀបចំផែនការតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- រៀបចំ និងកែសម្រួលស្ថាប័នកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំ និងកែសម្រួលឧបករណ៍កសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំ និងកែសម្រួលក្របខ័ណ្ឌពេលវេលានៃការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំ និងកែសម្រួលស្ថាប័នគាំទ្រការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៧.១. យុទ្ធសាស្ត្រទី១ "រៀបចំផែនការតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ"

ផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំតាមចរិតលក្ខណៈនៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលក្នុងនោះរួមមាន ៖

- **ផែនការរាជធានី** ជាផែនការដែលមានបញ្ចូលគ្នានូវផែនការរបស់រាជធានីផ្ទាល់ និងផែនការរបស់រដ្ឋបាលនានាចំណុះរាជធានី (ខណ្ឌ និងសង្កាត់ក្នុងរាជធានី) ឲ្យទៅជាផែនការរួមមួយដោយធានាបាននូវស្វ័យភាព ការផ្សារភ្ជាប់ និងស៊ីសង្វាក់គ្នាក្នុងការអភិវឌ្ឍ (ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាកម្ម) ក្នុងរាជធានី និងក្នុងរដ្ឋបាលចំណុះទាំងនោះ។ ផែនការរបស់រដ្ឋបាលចំណុះរាជធានី រួមមាន ផែនការខណ្ឌ និងផែនការសង្កាត់។ ផែនការខណ្ឌ គឺជាផែនការដែលមានការសម្របសម្រួល ការបំពេញបន្ថែម និងការគាំទ្រដល់ផែនការសង្កាត់។ ផែនការសង្កាត់ក្នុងខណ្ឌ ជាផែនការដែលរៀបចំឡើងដោយមានការពិភាក្សា និងពិគ្រោះយោបល់ផ្ទាល់ជាមួយប្រជាពលរដ្ឋនៅក្នុងសង្កាត់នីមួយៗ។ ផែនការខណ្ឌ និងផែនការសង្កាត់ ជាសមាសភាគនៃផែនការរាជធានី។ ការពិគ្រោះយោបល់ និងការចូលរួមរបស់ប្រជាពលរដ្ឋ វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ក្នុងដំណើរការរៀបចំផែនការរាជធានី ផែនការខណ្ឌ និងផែនការសង្កាត់ចំណុះរាជធានី គឺជាគោលការណ៍សំខាន់ និងចាំបាច់។
- **ផែនការខេត្ត** ជាផែនការដែលមានការសម្របសម្រួលរវាងផែនការខេត្តជាមួយផែនការក្រុង ស្រុក និងឃុំ សង្កាត់ក្នុងខេត្ត និងជាផែនការដែលត្រូវបំពេញបន្ថែម និងគាំទ្រដល់ផែនការក្រុង ស្រុក និងឃុំ សង្កាត់ក្នុងខេត្តនោះ សំដៅបង្កើនប្រសិទ្ធភាពនៃការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍នៅមូលដ្ឋាន។ ផែនការខេត្តមិនមែនជាផែនការដែលកើតចេញពីការបូកបញ្ចូលគ្នានូវផែនការក្រុង ស្រុក និងឃុំ សង្កាត់ទាំងអស់ក្នុងខេត្តនោះឡើយ។ ការពិគ្រោះយោបល់ និងការចូលរួមរបស់ប្រជាពលរដ្ឋ វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា គឺជាគោលការណ៍សំខាន់ និងចាំបាច់នៅក្នុងដំណើរការកសាងផែនការខេត្ត។

- **ផែនការទីប្រជុំជន (ក្រុង សង្កាត់)** ជាផែនការដែលដាក់បញ្ចូលគ្នានូវផែនការក្រុង និងផែនការសង្កាត់នានាចំណុះក្រុងនោះ។ ការដាក់បញ្ចូលគ្នានេះត្រូវគោរពស្វ័យភាពរបស់រដ្ឋបាលសង្កាត់នានាចំណុះក្រុង ដើម្បីផ្សារភ្ជាប់ និងធានាឲ្យមានភាពស៊ីសង្វាក់គ្នាក្នុងការអភិវឌ្ឍ (ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាកម្ម) ក្នុងក្រុងនោះ។ ផែនការសង្កាត់ក្នុងក្រុងជាផែនការដែលបានរៀបចំឡើងដោយមានការពិភាក្សា និងពិគ្រោះយោបល់ ផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងសង្កាត់។ ផែនការសង្កាត់ជាសមាសភាគនៃផែនការក្រុង។ ការពិគ្រោះយោបល់ និងការចូលរួមរបស់ប្រជាពលរដ្ឋ វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា គឺជាគោលការណ៍សំខាន់ និងចាំបាច់ក្នុងដំណើរការកសាងផែនការទីប្រជុំជន។
- **ផែនការទីជនបទ (ស្រុក ឃុំ)** ជាប្រភេទផែនការស្រុក និងផែនការឃុំក្នុងស្រុក។ ផែនការស្រុក គឺជាផែនការដែលមានការសម្របសម្រួលគ្នារវាងផែនការស្រុកជាមួយនឹងផែនការឃុំ ដើម្បីធានាថា ផែនការស្រុកបំពេញបន្ថែម និងគាំទ្រដល់ផែនការឃុំក្នុងស្រុកនោះ សំដៅបង្កើនប្រសិទ្ធភាពនៃការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍នៅមូលដ្ឋាន។ ផែនការស្រុក មិនមែនជាប្រភេទផែនការ ដែលកើតចេញពីការបូកបញ្ចូលគ្នានូវផែនការរបស់ឃុំទាំងអស់ក្នុងស្រុកនោះឡើយ។ ផែនការឃុំ ជាផែនការដែលមានការពិភាក្សា ពិគ្រោះយោបល់ផ្ទាល់ជាមួយប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានាក្នុងឃុំនោះ។ ផែនការឃុំមិនមែនជាសមាសភាគនៃផែនការស្រុកឡើយ។

**៧.២. យុទ្ធសាស្ត្រទី២ “រៀបចំ និងកែសម្រួលស្ថាប័នកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ”**

យន្តការចម្បងៗនានាដែលមានភារកិច្ចជួយក្រុមប្រឹក្សាក្នុងការរៀបចំ និងកសាងផែនការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន :

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស (សម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)
- គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ (សម្រាប់រដ្ឋបាលឃុំ សង្កាត់)

**ក). គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

ការកសាងផែនការរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាដំណើរការប្រព្រឹត្តទៅទាំងនយោបាយ និងបច្ចេកទេស ដែលទទួលខុសត្រូវ និងដឹកនាំដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមានការចូលរួមផ្នែកបច្ចេកទេសពីគណៈអភិបាល និងអង្គភាពជំនាញនានាក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺជាគណៈកម្មាធិការមួយរបស់ក្រុមប្រឹក្សា ដែលមានតួនាទីជួយសិក្សា និងផ្តល់យោបល់ជូនក្រុមប្រឹក្សា និងគណៈអភិបាលលើបញ្ហាពាក់ព័ន្ធនឹងការងារផែនការ ថវិកា និងការសម្របសម្រួលកិច្ចការនានាជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងជាមួយក្រុមប្រឹក្សាប្រភេទផ្សេងៗទៀត។

ពាក់ព័ន្ធនឹងការងារផែនការ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺជាយន្តការមួយយ៉ាង

សំខាន់ក្នុងការធានាឲ្យមានការដាក់បញ្ចូលនូវផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលបានផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ លើសពីនេះទៀត គណៈកម្មាធិការនេះត្រូវជួយក្រុមប្រឹក្សាពាក់ព័ន្ធនឹងការរៀបចំផែនការ និងថវិកាប្រចាំឆ្នាំ ការងារហិរញ្ញវត្ថុ និងថវិការបស់ក្រុមប្រឹក្សា ការវិភាជន៍មូលនិធិសម្រាប់គាំទ្រគម្រោងវិនិយោគនានា ការកៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធដល់គម្រោងវិនិយោគរបស់ក្រុមប្រឹក្សា ព្រមទាំងការងាររបាយការណ៍អំពីការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផងដែរ។ ក្នុងការអនុវត្តតួនាទី ភារកិច្ចទាំងនេះ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវប្រើប្រាស់ និងពង្រឹង ឬកែសម្រួលយន្តការនានាដែលមានស្រាប់ ឬអាចស្នើសុំបង្កើតយន្តការផ្សេងៗទៀតតាមការចាំបាច់។

ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺជាលក្ខខណ្ឌចាំបាច់ ដើម្បីធានាឲ្យគណៈកម្មាធិការមួយនេះអាចក្លាយជាអង្គភាពខួរក្បាលមួយយ៉ាងសំខាន់សម្រាប់ជួយផ្តល់ប្រឹក្សាយោបល់ដល់គណៈអភិបាល និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន។

**ខ). គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់**

នៅថ្នាក់ឃុំ សង្កាត់ មេឃុំ ចៅសង្កាត់បានបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកាសម្រាប់ឃុំ សង្កាត់របស់ខ្លួន។ គណៈកម្មាធិការនេះ គឺជាយន្តការសំខាន់មួយសម្រាប់ជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់។

**៧.៣. យុទ្ធសាស្ត្រទី៣ “រៀបចំ និងកែសម្រួលឧបករណ៍កសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ”**

ដើម្បីឆ្លុះបញ្ចាំង និងរំលេចឲ្យឃើញច្បាស់នូវរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនៅក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគដូចខាងក្រោម :

**ក). ផែនការអភិវឌ្ឍន៍**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវរៀបចំកសាងផែនការអភិវឌ្ឍន៍សម្រាប់រដ្ឋបាលរបស់ខ្លួនដែលឆ្លុះបញ្ចាំងអំពី ១).ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា និង២). កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ។

- **ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា** ជាផែនការដែលមានចរិតជាទស្សនៈអភិវឌ្ឍន៍រួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលនូវគោលដៅអភិវឌ្ឍន៍របស់ក្រសួង ស្ថាប័ន ឬអង្គភាពនានារបស់រាជរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនដែលបានផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនោះ។

- **កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ** ជារបៀបវារៈ ឬកម្មវិធីជាក់ស្តែង ដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗចង់សម្រេចបានក្នុងអាណត្តិខ្លួន សម្រាប់បង្ហាញពីគណនេយ្យភាពរបស់ខ្លួនចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល។ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន មានសមាសភាគ ១).ក្របខ័ណ្ឌវិនិយោគ ២).ក្របខ័ណ្ឌផ្តល់សេវាកម្ម និង៣).ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន ដោយផ្អែកតាមធនធាន មុខងារ សិទ្ធិអំណាចរបស់ខ្លួន និងខ្លឹមសារនៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ខ្លួន។ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន ជាឯកសារសម្រាប់ពិចារណានៅពេលរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកា និងសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខ). កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន។ កម្មវិធីវិនិយោគនេះ ជាក្របខ័ណ្ឌវិនិយោគរយៈពេលមធ្យមសម្រាប់អនុវត្តកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ។ អាស្រ័យហេតុនេះ កម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវរៀបចំឡើងដោយផ្អែកតាមកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ កម្មវិធីវិនិយោគបីឆ្នាំរំកិលមានបីផ្នែកគឺ ១).កម្មវិធីវិនិយោគ ២).កម្មវិធីប្រតិបត្តិការសេវាកម្ម និង៣).ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តិ។

- **កម្មវិធីវិនិយោគ** ជាគម្រោងវិនិយោគដែលមានពេលចាប់ផ្តើម និងបញ្ចប់ច្បាស់លាស់ ដែលរៀបចំឡើងសំដៅបង្កើតឡើងនូវហេដ្ឋារចនាសម្ព័ន្ធ ទ្រព្យសម្បត្តិសាធារណៈ និងសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។
- **កម្មវិធីប្រតិបត្តិការសេវាកម្ម** ជាសកម្មភាពផ្តល់សេវាសាធារណៈនានាជាប្រចាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗជូនប្រជាពលរដ្ឋរបស់ខ្លួន។ កម្មវិធីប្រតិបត្តិការសេវាកម្មនេះ អាចរួមបញ្ចូលនូវការអនុវត្តមុខងារ និងធនធាននានា ដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនោះផងដែរ។
- **ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា** ជាសកម្មភាព ឬផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការរៀបចំ និងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីឆ្លើយតបនឹងតម្រូវការ និងឱកាសក្នុងមូលដ្ឋាន។

## ៧.៤. យុទ្ធសាស្ត្រទី៤ "រៀបចំ និងកែសម្រួលក្របខ័ណ្ឌពេលវេលានៃការកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ"

ក្របខ័ណ្ឌពេលវេលាសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានភាពស៊ីសង្វាក់គ្នារវាងថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងជាមួយពេលវេលានៃការកសាងផែនការរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ។ ការបន្សុីពេលវេលានេះ គឺជាប្រការចាំបាច់បំផុតក្នុងការបង្កលក្ខណៈងាយស្រួលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័ននៅថ្នាក់ជាតិធ្វើការសម្របសម្រួលការគាំទ្រ និងការដាក់បញ្ចូលសកម្មភាពរបស់ខ្លួនទៅក្នុងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

លើសពីនេះទៀត ក្របខ័ណ្ឌពេលវេលាសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវស៊ីសង្វាក់ជាមួយប្រតិទិនរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការវិភាជន៍ និងប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពដែលបានកំណត់។

### ៧.៥. យុទ្ធសាស្ត្រទី៥ "រៀបចំស្ថាប័នគាំទ្រការកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ"

ដើម្បីជួយឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចរៀបចំកសាងផែនការរបស់ខ្លួនបាន ស្របតាមយុទ្ធសាស្ត្រទី១ យុទ្ធសាស្ត្រទី២ យុទ្ធសាស្ត្រទី៣ និងយុទ្ធសាស្ត្រទី៤នៃគោលនយោបាយនេះ ក្រសួងផែនការត្រូវសម្របសម្រួលជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗ ធ្វើការរៀបចំ ចាត់ចែង និងដឹកនាំក្នុងការផ្តួចផ្តើម ពិនិត្យកែសម្រួល និងរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងត្រូវធ្វើការផ្សព្វផ្សាយ ណែនាំ តម្រង់ទិសការអនុវត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិឲ្យមានប្រសិទ្ធភាព។

## ៨. ផែនការសកម្មភាព

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រ នៃគោលនយោបាយនេះ ផែនការសកម្មភាពដែលត្រូវអនុវត្តជាចាំបាច់ រួមមាន :

- រៀបចំ និងផ្សព្វផ្សាយគោលនយោបាយនេះដល់ក្រសួង ស្ថាប័ន និងដល់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់
- ពិនិត្យ និងកែសម្រួលអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សិក្សា និងធ្វើបច្ចុប្បន្នកម្មលើសេចក្តីណែនាំស្តីពីការបង្កើតយន្តការផ្សេងៗ សម្រាប់អនុវត្តកិច្ចការនានា ក្នុងក្របខ័ណ្ឌផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិការបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ពិនិត្យ និងកែសម្រួលប្រកាសអន្តរក្រសួង និងសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីនិយោគបីឆ្នាំរំកិលរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ពិនិត្យ និងកែសម្រួលប្រកាសអន្តរក្រសួង និងសេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីនិយោគឃុំ សង្កាត់
- អភិវឌ្ឍសមត្ថភាព អំពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- រៀបចំសេចក្តីណែនាំស្តីពីការរៀបចំរបាយការណ៍វឌ្ឍនភាពក្នុងការអនុវត្តកម្មវិធីវិនិយោគ និងការតាមដានត្រួតពិនិត្យ វាយតម្លៃលើកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវកសាងផែនការរបស់ខ្លួនតាមបទបញ្ញត្តិនានាដែលបានកែសម្រួលនេះ។

## ៩. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) មានតួនាទីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចដំណើរការអនុវត្តគោលនយោបាយស្តីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ១០. សេចក្តីសន្និដ្ឋាន

គោលនយោបាយស្តីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនេះ នឹងរួមចំណែកដល់ការពង្រឹងប្រព័ន្ធផែនការតាមបែបវិមជ្ឈការ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានស្វ័យភាពក្នុងការរៀបចំផែនការតាមដែនសមត្ថកិច្ច និងអាណត្តិរបស់ខ្លួន។ គោលនយោបាយនេះបញ្ជាក់ពីភាពខុសគ្នារវាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា ដែលជាផែនការរួមនៅថ្នាក់រដ្ឋបាលរបស់ខ្លួន និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន ដែលជាផែនការផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានជាផែនការដែលមានការចូលរួមរៀបចំ និងចូលរួមអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធនៅក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងជាកម្មវិធីនយោបាយជាក់ស្តែង ដែលក្រុមប្រឹក្សាមានគោលបំណងចង់សម្រេចបានក្នុងអាណត្តិរបស់ខ្លួន និងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់បញ្ជាក់ពីគណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល ហើយក៏ជាឯកសារគោលសម្រាប់វាស់វែងពីកម្រិតបំពេញកិច្ចការរបស់ក្រុមប្រឹក្សាក្នុងអាណត្តិរបស់ខ្លួនផងដែរ។

គោលនយោបាយនេះ បានបកស្រាយយ៉ាងច្បាស់អំពីការបង្កើតប្រព័ន្ធគាំទ្រដ៏មានប្រសិទ្ធភាពមួយ ដើម្បីគាំទ្រការកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចធានាបាននូវការអភិវឌ្ឍសមត្ថភាព និងគុណភាពនៃការរៀបចំផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៅមូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបយ្យនៅថ្នាក់ក្រោមជាតិ៕